**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ: ៦៤ . សសរ**

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មាធិការសម្របសម្រួល អនុវត្តន៍ កាតព្វកិច្ចក្រោម ក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក និងរៀបចំឯកសារសម្រាប់ត្រួតពិនិត្យគោលនយោបាយពាណិជ្ជកម្មកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើត "គណៈកម្មាធិការសម្របសម្រួលអនុវត្តន៍ កាតព្វកិច្ចក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក និងរៀបចំឯកសារសម្រាប់ត្រួតពិនិត្យគោលនយោបាយពាណិជ្ជកម្មកម្ពុជា"

ហៅកាត់ថា គ.អ.ក.ព ដើម្បីសម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ សំដៅអនុវត្តន៍កាតព្វកិច្ចរបស់កម្ពុជាក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក និងរៀបចំឯកសារនានាសម្រាប់កិច្ចប្រជុំត្រួតពិនិត្យ គោលនយោបាយពាណិជ្ជកម្មកម្ពុជា។

គ.អ.ក.ព មានលេខាធិការដ្ឋាននៅ ក្រសួងពាណិជ្ជកម្ម។ ការរៀបចំ និងប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន គ.អ.ក.ព ត្រូវកំណត់ដោយប្រធាន គ.អ.ក.ព ។

**ប្រការ ២.**

គ.អ.ក.ព មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១. រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | ប្រធាន |
| ២. រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៣. រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤. រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ៥. រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៦. រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៧. រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៨. រដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល | សមាជិក |
| ៩. រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១០. រដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ១១. រដ្ឋលេខាធិការក្រសួងអបរំ យុវជន និងកីឡា | សមាជិក |
| ១២. រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ១៣. រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ | សមាជិក |
| ១៤. រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ១៥. រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ១៦. រដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ១៧. រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ១៨. រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១៩. រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ២០. រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ២១. រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ២២. រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ២៣. រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ២៤. អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ២៥. អនុរដ្ឋលេខាធិការ រដ្ឋលេខាធិការដ្ឋាន អាកាសចរណ៍ស៊ីវិល | សមាជិក |

២៦. អគ្គលេខាធិការរងគណៈកម្មការវិនិយោគនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក
២៧. ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សមាជិក

**ប្រការ ៣.**_

គ.អ.ក.ព មានភារកិច្ចដូចខាងក្រោម៖

- តាមដាន និងសម្របសម្រួលការអនុវត្តកាតព្វកិច្ច និងការសន្យាដែលបានធ្វើឡើងក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោកដើម្បីរាយការណ៍ជូនរាជរដ្ឋាភិបាល អំពីវឌ្ឍនភាពការងារ និងទិសដៅដែលត្រូវធ្វើបន្ត
- រៀបចំលិខិតបទដ្ឋានគតិយុត្តិថ្មី ឬ លើកទិសដៅសម្រាប់ធ្វើវិសោធនកម្មលិខិតបទដ្ឋានច្បាប់ជាធរមាន និងកែលម្អគោលនយោបាយពាណិជ្ជកម្ម ឲ្យមានអនុលោមភាព និងសង្គតិភាពជាមួយការសន្យាក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក
- រៀបចំឯកសារ និងផ្តល់អនុសាសន៍ជូនរាជរដ្ឋាភិបាល សម្រាប់ចរចាជាមួយបណ្តាប្រទេសក្នុងបរិបទពាណិជ្ជកម្មតំបន់ និងពិភពលោក
- ចងក្រងឯកសារគោលនយោបាយទាក់ទងនិងពាណិជ្ជកម្ម សម្រាប់កិច្ចប្រជុំត្រួតពិនិត្យគោលនយោបាយពាណិជ្ជកម្ម នៅក្នុងក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក
- គៀងគរថវិកាពីដៃគូអភិវឌ្ឍន៍នានាសម្រាប់ជួយដល់ ក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងការអនុវត្តកាតព្វកិច្ច និងការសន្យាក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក
- ចូលរួម និងសម្របសម្រួលដល់ការរៀបចំកិច្ចប្រជុំនានា ពាក់ព័ន្ធនិងការត្រួតពិនិត្យ គោលនយោបាយពាណិជ្ជកម្មកម្ពុជា ទាំងក្នុងប្រទេស និងក្រៅប្រទេស
- អនុវត្តន៍ភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន

**ប្រការ ៤.**_

អនុប្រធាន និងសមាជិក គ.អ.ក.ព ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន ឬមានភារកិច្ចផ្សេង អនុប្រធានត្រូវដឹកនាំប្រជុំជំនួស តាមការប្រគល់ភារកិច្ចពីប្រធាន។ ប្រធាន គ.អ.ក.ព អាចអញ្ជើញមន្ត្រីតំណាងក្រសួង-ស្ថាប័នផ្សេងទៀតឲ្យចូលរួមប្រជុំតាមការចាំបាច់។

**ប្រការ ៥.**_

ការចំណាយសម្រាប់ដំណើរការ គ.អ.ក.ព ត្រូវយកពីថវិកាជាតិ ក្នុងគម្រោងថវិការបស់ក្រសួងពាណិជ្ជកម្ម ឬថវិកាទទួលបានពីប្រភពស្របច្បាប់ផ្សេងទៀត។

**ប្រការ ៦.**_

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវអនុវត្តន៍សេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ២ (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ខុទ្ទកាល័យសម្តេចតេជោ (វិមានសន្តិភាព)
ចូល លេខ ៖ ៥០៧
ថ្ងៃទី ៖ 06/07/16
ម៉ោង ៖ 3h20

ក្រសួងពាណិជ្ជកម្ម

លេខ ២៧៦៣ ព.ណ.ខកល

រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៦

ទីស្តីការគណៈរដ្ឋមន្ត្រី
ចូល លេខ 1880
ថ្ងៃ 06 ខែ 07 ឆ្នាំ 2016
ម៉ោង 15h05

**សូមគោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ:** សំណើសុំការពិនិត្យ សម្រេច និងចុះហត្ថលេខាលើសេចក្តីសម្រេច ស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលអនុវត្តន៍កាតព្វកិច្ចក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក និងរៀបចំឯកសារសម្រាប់ត្រួតពិនិត្យគោលនយោបាយពាណិជ្ជកម្មកម្ពុជា។

**យោង:** ចំណារឯកភាពចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៦ របស់ **ឯកឧត្តម ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជាប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី លើលិខិតរបស់ក្រសួងពាណិជ្ជកម្ម លេខ ១៧១៣ ព.ណ ខកល ចុះថ្ងៃទី ១៦ខែឧសភា ឆ្នាំ២០១៦។

**ជូនភ្ជាប់:** សេចក្តីព្រាងសេចក្តីសម្រេច ស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលអនុវត្តន៍កាតព្វកិច្ចក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយសគោរពជម្រាបជូន **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា៖ ដោយមានការឯកភាពពី **ឯកឧត្តម ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ តាមការប្រទានសិទ្ធិរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ក្រសួងពាណិជ្ជកម្មបានធ្វើសេចក្តីព្រាងសេចក្តីសម្រេចស្តីពី ការបង្កើតគណៈកម្មាធិការសម្របសម្រួលអនុវត្តន៍កាតព្វកិច្ចក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក និងរៀបចំឯកសារសម្រាប់ត្រួតពិនិត្យគោលនយោបាយពាណិជ្ជកម្មកម្ពុជាដើម្បីដាក់ជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យ សម្រេច និងចុះហត្ថលេខាដ៏ខ្ពង់ខ្ពស់។

អាស្រ័យហេតុដូចបានគោរពជម្រាបជូនខាងលើ សូម **សម្តេចតេជោនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចចុះហត្ថលេខា ដោយក្តីអនុគ្រោះបំផុត។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុត អំពីខ្ញុំបាទ ។

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

7.7.16

**ប៉ាន សូរស័ក្តិ**

ឡូត៍លេខ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ) . ភូមិទឹកថ្លា
សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ / ទូរសារ:(៨៥៥) -២៣ ៨៦៦ ៤២៥